# របៀបរៀបចំពិធីបញ្ចុះខណ្ឌសីមា

## សីមាជាអ្វី

## ផ្លូវសុខ ៣ យ៉ាង



ស្ថាបនាបន្តពីលើគ្រឹះចាស់ : ក្នុងឆ្នាំ ១៩៩២

បញ្ចុះសីមា : ថ្ងៃ សៅរ៍ ១២ កើត ខែ ជេស្ឋ ឆ្នាំកុរ

សប្តស័ក ពុទ្ធសករាជ ២៥៣៩

ត្រូវនឹងថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៥

បណ្ណាល័យ
LIBRARY
INST.

២១៣.
៧

www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្ហូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

១១៣.៧

# របៀបរៀបចំពិធីបញ្ចុះខណ្ឌសីមា

## សីមាជាអ្វី

## ផ្លូវសុខ ៣ យ៉ាង

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៧៤១៩/៩៦

ចែកជាធម្មទាន
ក្នុងឱកាសបុណ្យបញ្ចុះខណ្ឌសីមា

## វត្ត គោករម្លិល

ឃុំជើងឯក ស្រុកដង្កោ រាជធានីភ្នំពេញ

ព.ស ២៥៣៩ គ.ស ១៩៩៥

www.budinst.gov.kh www.elibraryofcambodia.org



ឯកឧត្តម គ្រីយ៍ បេងហុង
និងលោកជំទាវ ម៉ម ដួងសុជាតិ

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅ « របៀបរៀបចំបុណ្យបញ្ចុះខណ្ឌសីមា ស៊ីមាជាអ្វី និង ផ្លូវសុខ ៣ យ៉ាង » នេះកើតឡើងដោយគំនិតផ្តួចផ្តើមរបស់ ឯកឧត្តម **ក្រើយ៍ បេចហុខ** អភិបាលរង រាជធានីភ្នំពេញ និង លោកជំទាវ **ម៉ម ជួចសុជាតិ** ដែលមានសទ្ធាជ្រះថ្លាដ៏ជ្រាលជ្រៅក្នុងព្រះពុទ្ធសាសនា ហើយមានបំណងចង់បានសៀវភៅធម៌ចែកជាធម្មទាន ក្នុងឱកាសបុណ្យបញ្ចុះសីមា ព្រះវិហារវត្ត **ធីសភារៈ គោកពីស្សីរកយ៉** ហៅវត្ត **គោក អម្ពិល** ឃុំជើង ឯក ស្រុកដង្កោ រាជធានីភ្នំពេញ ។

ព្រះវិហារវត្ត **គោកអម្ពិល**នេះ ឯកឧត្តម **ក្រើយ៍ បេចហុខ** និង លោកជំទាវ បានចំណាយទ្រព្យយ៉ាងច្រើន រួមជាមួយពុទ្ធបរិស័ទចំណុះជើងវត្ត និង ទីជិតឆ្ងាយ កសាងឡើងវិញជាថ្មី នៅលើខឿនចាស់ តាំងពីឆ្នាំ ១៩៩២ និងបានរួចរាល់ជាស្ថាពរ នៅឆ្នាំ ១៩៩៥ ប្រារព្ធពិធីបញ្ចុះខណ្ឌសីមា នៅថ្ងៃ សៅរ៍ ១២ កើត ខែ ជេស្ឋ ឆ្នាំកុរ ព.ស ២៥៣៩ ត្រូវនឹងថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

ខ្ញុំមានអំណរសាទរប្រកបដោយទឹកចិត្តជ្រះថ្លាដ៏ស្មោះសរ សូមរួមចំណែកក្នុងកងការកុសលនេះ ដោយបានជ្រើសរើសយកអត្ថបទធម៌ ស្តីពីរបៀបរៀបចំពិធីបុណ្យបញ្ចុះខណ្ឌសីមា ផលប្រយោជន៍នៃសីមា និង

www.budinst.gov.kh www.elibraryofcambodia.org

ផ្លូវសុខ ៣ យ៉ាង ដែលសម្ដេចព្រះមង្គលទេពាចារ្យ **អ៊ុំ ស៊ុំ** និង ព្រះមហាព្រហ្មមុនី **ហេង លាងហោ** បានជួយផ្ទៀងផ្ទាត់រួចហើយ ចងក្រងបោះពុម្ពជាសៀវភៅ ដើម្បីទុកជាឯកសារ សម្រាប់ព្រះសង្ឃ គ្រហស្ថ សិក្សាស្រាវជ្រាវ តទៅអនាគត ។

សូមលើកយកមហាកុសលដែលកើតឡើងពីធម្មទាននេះ ជូនចំពោះបុព្វការីជន មានមាតា បិតា ជាដើម របស់ឯកឧត្ដម **ត្រឹយ៍ បេងហុង** និង លោកជំទាវ **ម៉ម ជួនសុជាតិ** សូមឱ្យលោកទទួលយកភាគផលកុសលនេះដោយសោមនស្ស និង សូមបានទៅសោយសុខក្នុងសុគតិភពក្នុង អនាគតជាតិ ។

សូមប្រគេន-ជូនកុសលនេះ ចំពោះព្រះសង្ឃគ្រប់អង្គ ពុទ្ធបរិស័ទគ្រប់រូប និង ប្រជាពលរដ្ឋខ្មែរទាំងអស់ សូមបានប្រកបដោយពរទាំង ៥ ប្រការគឺ : អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភានៈ ជានិច្ចនិរន្តរ៍តរៀងទៅ។

សូមមាតុភូមិកម្ពុជា បានសុខសន្តិភាព និង សំបូររុងរឿង ។

ភ្នំពេញ , ថ្ងៃទី ៩ ខែ មិថុនា ព.ស ២៥៣៩<br>គ.ស ១៩៩៥

**អ្នកស្រាវជ្រាវ**

www.budinst.gov.kh www.elibraryofcambodia.org

# របៀបរៀបចំពិធីបញ្ចុះខណ្ឌសីមា

ព្រះវិហារជាទីសេនាសនៈ ពិសេសជាងសេនាសនៈផងទាំងពួងនៅក្នុងវត្តអារាមនិមួយៗ ព្រោះជាឧបោសថាគារ សម្រាប់សង្ឃធ្វើសង្ឃកម្មផ្សេងៗ មានឧបោសថកម្ម ជាដើម ។ ជាការចាំបាច់ពីបុរាណមក កាលណាគេកសាងព្រះវិហាររួចរាល់ជាស្ថាពរហើយ គេតែងប្រារព្ធពិធីបញ្ចុះខណ្ឌសីមា សម្ពោធឆ្លងបើកអោយប្រើប្រាស់តរៀងទៅ ។ បុណ្យបញ្ចុះខណ្ឌសីមានេះ រាប់ថាជាបុណ្យដ៏សំខាន់របស់ប្រជាជនខ្មែរ ជាពុទ្ធសាសនិក គេរៀបចំពិធីនេះយ៉ាងមហោឡារិក ។ អ្នកខ្លះមានជំនឿថា បើអ្នកណាធ្វើបុណ្យបញ្ចុះសីមា គ្រប់ ៧ វត្តអ្នកនោះឯងនឹងបានរំដោះកម្មពៀរវេរាផងទាំងឡាយពុំខាន ។ ព្រោះហេតុនោះហើយបានជា ក្នុងឱកាសបុណ្យបញ្ចុះសីមាម្តងៗ គេឃើញមានមនុស្សម្នាមហាជន ចាស់ ក្មេង ប្រុស ស្រី ចូលរួមអនុមោទនាអបអរសាទរ សប្បាយរីករាយដោយទឹកចិត្តជ្រះថ្លា និងប្រកប ដោយកុសលខ្ពស់ ។

www.budinst.gov.kh www.elibraryofcambodia.org

តាមព្រះវិន័យក្នុងព្រះពុទ្ធសាសនា ព្រះវិហារណាដែលពុំទាន់បាន បញ្ចុះខណ្ឌសីមា ព្រះវិហារនោះពុំអាចចាត់ទុកថាជា ឧបោសថាគារ ពេញ លក្ខណៈឡើយ ។ ព្រោះហេតុនោះហើយបានជា ការរៀបចំពិធីបញ្ចុះសីមា ត្រូវប្រព្រឹត្តទៅនៅក្នុងក្របខ័ណ្ឌ ព្រះវិន័យឲ្យបានល្អបំផុត អាស្រ័យ ដោយសង្ឃញ្ញាសប្រតិពល ជាអ្នកចាត់ចែងការងារនេះ ។

និមិត្តសីមាដែលជាគោលព្រំដែននៃផ្ទៃដីដ៏ពិសិដ្ឋនេះមាន ៩ គឺ : សីមា ៨ សម្រាប់ដាក់ប្រចាំទិសធំបួន និង ទិសតូចបួនឬច្រើនជាងនេះក៏ បាន ។ និមិត្តសីមាមួយទៀតសម្រាប់ដាក់ចំកណ្ដាលព្រះវិហារ ចំពោះ ព្រះភ័ក្រព្រះជីវ័ធំ ។

និមិត្តសីមាដែលដាក់ប្រចាំទិស ៨ នៅបរិវេណជុំវិញព្រះវិហារនោះ គេត្រូវធ្វើមានឫសមួយដែលត្រូវកប់ទៅក្នុងដី និងមានសន្លឹកមួយផ្ទាំង មាន សណ្ឋានជាសិលាស្តម្ភ ឆ្លាក់ជារូបទេព្ដា កាន់ផ្កាឈូកប្រណម្យហៅថា «**ទេព្យប្រណម្យ**» ។

ក្នុងសម័យពុទ្ធកាល នៅពេលបញ្ចុះសីមានៃព្រះវិហារវត្តជេតពន ដែលជាព្រះបឋមវិហារ ព្រះឥន្ទ្រាធិរាជ ទ្រង់បានយាងចុះមកកាន់សីមា

www.budinst.gov.kh www.elibraryofcambodia.org

ដែលស្ថិតនៅកណ្ដាលព្រះវិហារ ។ ហេតុនេះហើយបានជាអ្នកប្រាជ្ញអោយឈ្មោះ សីមានេះថាជា « **សីមាឥន្ទខិល** » (១) ហើយសីមានេះមានតែឫស ឥតមានស្លឹកផ្ដាំងផ្ទនៅពីលើទេ ។

ឫស សីមានីមួយៗគេធ្វើអំពីថ្ម មូយដុំមានរាងមូលដូចគ្រាប់ផ្លោងផ្ទាប់ទម្ងន់ ៦៤ នាឡិ តាមវិន័យព្រះពុទ្ធសាសនា គេត្រូវយកស្ករអំពៅទៅថ្លឹងបានទម្ងន់ ៦៤ នាឡិ ហើយពូតបានទំហំប៉ុណ្ណា ត្រូវធ្វើដុំថ្មប៉ុណ្ណោះ ។

មុននឹងកាត់ឫសសីមា គេត្រូវមើលពេលវេលាអោយហើយស្រេចដើម្បីនឹងប្រារព្ធពិធីកាត់ឫសសីមាទាំង ៩ ទិសនោះ អោយធ្លាក់ទៅក្នុងរណ្ដៅព្រមគ្នាតែម្ដង ។

តាមទម្លាប់ គេច្រើនរៀបចំពិធីកាត់ឫសសីមា នៅពេលព្រឹកព្រលឹមស្រាង ៗ ។

តាមប្រពៃណីពីបុរាណ បុណ្យបញ្ចុះសីមា គេត្រូវធ្វើអស់រយៈពេល ៣ ឬ ៤ ថ្ងៃយ៉ាងតិច ។ ពេលនោះគេត្រូវនិមន្តព្រះសង្ឃ ២១ អង្គយ៉ាង តិច ពីគ្រប់វត្តចំនួន ២១ វត្តដែរ ។ ពុទ្ធបរិស័ទ នាំគ្នាធ្វើរោង

(១) ពាក្យបាលីថា « ឥន្ទខិល ឬ សំស្ក្រឹតថា ឥន្ទ្រកិល » ប្រែថា « សរសេរគោល ឬ គោលព្រំដែន »

www.budinst.gov.kh www.elibraryofcambodia.org

ក្រសាលប្រចាំទិសរៀងៗខ្លួនហើយមានកាន់រង្គប្រគេនបច្ច័យបួន ព្រះសង្ឃតាម សទ្ធាជ្រះថ្លា ។

នៅពេលនោះ គេអញ្ជើញលោកអាចារ្យ ៩ រូប អំពីវត្តផ្សេងៗមកកាន់រោងទិសដើម្បីធ្វើសក្ការបូជា និង បំពេញកិច្ចជាទំនៀមផ្សេងៗ តាមរោងរបស់ខ្លួនមានរានទេវតាប្រចាំទិសជាដើម ។ លោកអាចារ្យណាដែលបានចាប់ស្លាកទៅត្រូវបានរក្សារោងពិធីកណ្តាល អាចារ្យនោះត្រូវមើលការខុសត្រូវរានព្រះយមរាជ ហើយត្រូវទទួលភារៈជាអ្នកដឹកនាំពិធីទាំងពួងក្នុងបុណ្យនោះផង ។

ចំពោះពិធីបុណ្យនេះយើងពិពណ៌នាចំពោះតែគោលសំខាន់ៗ ដែលត្រូវរៀបចំធ្វើចាំបាច់ប៉ុណ្ណោះ ។

ជាធម្មតា នៅថ្ងៃទី ១ បុណ្យបញ្ចុះសីមាគេចាប់ផ្តើមធ្វើនៅថ្ងៃរសៀល ។ ទាយក ទាយិកា នាំគ្នាយកទឹកអប់ មាសសន្លឹក ឬសំពត់សទៅស្រោច ទៅស្រោបបិទលើឫស សីមា ដែលគេដាក់ផ្តុំគ្នានៅកណ្តាល ព្រះវិហារ រួចគេនាំគ្នាសែង ឫសសីមានោះ ដង្ហែ ប្រទក្សិណ ៣ ជុំ ព្រះវិហាររួចហើយទើបនាំចូលទៅតម្កល់ នៅកន្លែងដើមវិញ ។ បន្ទាប់មក គេវេរស៊ីថ្ម

www.budinst.gov.kh www.elibraryofcambodia.org

និមិត្តសីមា និងវេរភោងឧបោសថ ហើយនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត និង សម្តែងព្រះធម៌ទេសនា រហូតដល់អធ្រាត្រ ។

ព្រឹកថ្ងៃទី ២ ទាយក ទាយិកា រៀបចំកម្មវិធីប្រគេនយាគូ វេរភត្ត ប្រគេនសង្ឃជាប្រក្រតី ។ នៅពេលរសៀល និមន្តព្រះសង្ឃ ចំរើនព្រះ បរិត្ត និង សម្តែងព្រះធម៌ទេសនា ។ ចាប់ពីពាក់កណ្តាលអធ្រាត្រទៅទើប គេប្រារព្ធពិធីធ្វើពុទ្ធាភិសេក ។

ព្រឹកថ្ងៃទី ៣ កម្មវិធីរៀបចំប្រគេនយាគូ និងវេរភត្តប្រគេនសង្ឃ ដូចថ្ងៃទី ២ និងរៀបចំរណ្តៅសំរាប់ទទួលឫសសីមា ។ ជាធម្មតា រណ្តៅ នោះមានទទឹងរាត់ ១ ម និងមានជម្រៅ ១ ម សម្រាប់រណ្តៅទាំង ៨ ទិស នៅបរិវេណព្រះវិហារ ។ ប៉ុន្តែចំពោះសីមា កិល នៅមុខព្រះជីវ៍ធំ មានទំហំ មាត់ ១,៥០ ម បួនជ្រុងនិងជម្រៅ ២,៥០ ម ។ ឧបាសក ឧបាសិកា ទាយក ទាយិកា និង ប្រជាជន ប្រុស ស្រី ចាស់ ក្មេង នាំគ្នាយកវត្ថុផ្សេងៗ ទៅ បង់បូជាក្នុងរណ្តៅទាំងនោះ ជាពិសេសក្នុងរណ្តៅសីមាកិល ។ ខ្លះដាក់មាស ដាក់ប្រាក់ ដាក់កន្សែង សៀវភៅ ខ្មៅដៃ កញ្ចក់ ក្រាស់ ។ល។ រហូតខ្លះ កាត់សក់ដាក់ អ្នកខ្លះអារសាច់សប្រក់ឈាមដាក់ក៏មាន តាមសេចក្តី ប្រាថ្នា

www.budinst.gov.kh www.elibraryofcambodia.org

ចង់អោយមានទ្រព្យសម្បត្តិ ចង់អោយមានបញ្ញាភ្លឺថ្លាឈ្លាសវៃ ចេះចាំនូវវិជ្ជាផ្សេងៗចង់អោយបានរូបសម្បត្តិស្អាត ល្អទៅអនាគត ។

ដូច្នេះហើយបានជាមានអ្នកខ្លះជឿថា ដាក់សក់ដើម្បីអោយជាតិក្រោយបានសក់ល្អ សម្រក់ឈាមដាក់ដើម្បីអោយមានចិត្តក្លាហានទៅអនាគតជាតិជាដើម ។

នៅមាត់រណ្តៅសីមានីមួយៗ គេដាក់ឈើជាបង្គង យកអំបោះឆៅចងបន្តោង ឫសសីមា ដែលរុំដោយសំពត់ហូលពីក្រោម ។

លុះព្រះសង្ឃស្វាធ្យាយធម៌ស្រេចហើយ អាចារ្យវេរឫសសីមាប្រគេនសង្ឃ ។ បន្ទាប់មកអាចារ្យរៀបចំពាវាងផ្តៅលើផ្ទៃព្រះវិហារ ។ ឯក្រឡាពាវាងនោះអាចារ្យខ្លះថាត្រូវមានទំហំ ០,៥០ ម បួនជ្រុង ។ អាចារ្យខ្លះទៀតថាត្រូវមានទំហំ ល្មមតែចុះជើងទាំងពីរ ។ កាលបើអាចារ្យរៀបចំពាវាងរួចស្រេចហើយ គេប្រយ័ត្នមិនអោយមនុស្ស ឬ សត្វអ្វីចូល ក្នុងព្រះវិហារនោះឡើយ ។ ពួកអាចារ្យនាំគ្នាដើរមើលការពារមនុស្សម្នា និងសត្វផងទាំងពួងអោយចៀសចេញ ឆ្ងាយអំពី ព្រះសង្ឃបញ្ជាន់ពាវាង ព្រោះថា តែកាលណាមានសត្វ ឬ មនុស្ស ចូលក្នុងពេលដែលព្រះសង្ឃកំពុង

www.budinst.gov.kh www.elibraryofcambodia.org

សូត្របញ្ជាន់ពារាងនោះ គេសន្មត់ថា ដាច់ ឬ អន្តរាយសង្ឃកម្ម ត្រូវធ្វើសារឡើងវិញជាថ្មីទាំងអស់ ។ ដល់វេលាយប់ ព្រះសង្ឃរៀបចំធ្វើហត្ថបាសបញ្ជាន់ពារាងក្នុងព្រះវិហារ គឺកាលណាលោកសូត្រញត្តិចប់មួយវគ្គៗ ព្រះសង្ឃត្រូវនិមន្តទៅមុខមួយក្រឡា ។ ការធ្វើយ៉ាងនេះរហូតដល់សព្វទីពេញក្នុងព្រះវិហារ ។ ពិធីបញ្ជាន់ពារាងធ្វើអស់ពេលឆាប់ ឬយូរ ស្រេចលើចំនួនព្រះសង្ឃមានតិច ឬ ច្រើនប៉ុណ្ណោះ និងព្រះសង្ឃ មហាថេរអ្នកឈ្លាសប្រតិពលក្នុងការដឹកនាំ ព្រោះវត្តខ្លះមានព្រះសង្ឃរហូតទៅដល់រាប់រយអង្គម្ល៉ោះហើយការបញ្ជាន់ពារាង ក៏អាចសម្រេចទៅតាមនោះដែរ ។

ប៉ុន្តែបើដីនោះជាកន្លែងវត្តចាស់ ដែលគេបានបញ្ចុះខណ្ឌសីមាម្តងរួចហើយនោះ មុននឹងបញ្ចុះសីមាថ្មី សង្ឃត្រូវសូត្រដកឫសសីមាចាស់សិន ។ របៀបដកសីមាចាស់ត្រូវធ្វើដោយភិក្ខុពីរអង្គហើយត្រូវចាប់ធ្វើពីសីមាកិលជាដំបូង ។ បន្ទាប់មកលោកនិមន្តទៅកាន់សីមាទិសបូព៌រួចទៅសីមាទិស ឦសាន សីមាទិសឧត្តរ ជាបន្តបន្ទាប់រហូតដល់សីមាទិសអគ្នេយ៍ជាទីចុងបង្អើយ ។ លុះព្រះសង្ឃធ្វើកិច្ចដកឫសសីមាចាស់ស្រេចហើយអាចារ្យទាំង ៩ រូបចូលកាន់ឫសសីមាថ្មីរៀង១ខ្លួន ។ ព្រះសង្ឃមួយអង្គ

www.budinst.gov.kh www.elibraryofcambodia.org

និមន្តចូលទៅជិតសីមាហើយសួរអំពីនិមិត្តសីមាទិសបូព៌ាមុនទៅអាចារ្យថា «អ្វី ជានិមិត្តនៃមជ្ឈិមមណ្ឌល ?» លោកអាចារ្យឆ្លើយថា « **ថ្មព្រះករុណាម្ចាស់** » ។ ការសួរនិងឆ្លើយ ត្រូវធ្វើជាភាសាបាលិទាំងអស់ ។ ហើយព្រះសង្ឃនិមន្តធ្វើកិច្ចដដែលនេះតាមសីមាទិសដទៃៗទៀត ជាហូរហែទៅ ។ ឯពាក្យសួរ និងពាក្យឆ្លើយនៅដដែលទាំងអស់ ប្លែកតែឈ្មោះទិសប៉ុណ្ណោះ ។

បន្ទាប់មកទៀតព្រះសង្ឃនិមន្តមកប្រជុំនៅជុំវិញសីមាឥន្ទខិលៈហើយសូត្រញត្តិចង ដោយនិមន្តពីក្រឡាតារាងមួយទៅក្រឡាតារាងមួយទៀត និងពីរណ្ដៅសីមាមួយទៅរណ្ដៅសីមាមួយទៀត ។

ថ្ងៃបន្ទាប់មកទៀតជាថ្ងៃកាត់ឫសសីមា ។ ឫសសីមានោះត្រូវធ្លាក់ចុះព្រមគ្នាតែម្ដងនៅពេលជាមង្គលដែលគេបានជ្រើសរើសទុកជាមុន ។ ដើម្បីអោយបានស្មើគ្នា គេសន្មតតាមស្នូរស្គរ ឬ ឃ្មោះ ។ ស្នូរទី ១ ដំបូងអ្នកកាន់កាំបិត ទាំង ៩ នាក់ដាក់មុខ កាំបិតផ្ទួងលើខ្សែដែលចងឫសសីមា។ ឯអ្នកកាន់អន្លូងទាំង ៩ នាក់ទៀតដាក់អន្លូងជាប់ទៅលើខ្នងកាំបិត ដើម្បីប្រុងប្រៀប លៃប្រមាណដៃ ។ ស្នូរស្គរទី ២ គេលើកអន្លូងឡើងព្រមគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ដល់ស្នូរស្គរទី ៣ គេវាយ អន្លូងព្រិបព្រមគ្នាតែម្តងទៅលើកាំបិត អំពោះចងឫសក៏ដាច់ឫសសីមាក៏ធ្លាក់ ព្រមគ្នាទៅក្នុងរណ្តៅ ។

តាមជំនឿអ្នកស្រុក មនុស្សខ្លះ មើលពិធីកាត់ឫសសីមានេះពុំបានទេ ។ នៅតំបន់ខ្លះក្នុងពេលបុណ្យ លោក គ្រូចៅអធិការមិនត្រូវនិមន្តទៅណាទេ ។ នៅកន្លែងខ្លះទៀតថា បើឆ្នាំកំណើតលោកគ្រូចៅអធិការ ត្រូវគ្នានឹងឆ្នាំបញ្ចុះសីមានេះ លោកគ្រូចៅអធិការត្រូវនិមន្តចេញ អោយឆ្ងាយ លុះត្រាតែផុតស្នូរសន្ធឹកឫសសីមាធ្លាក់ ។

នៅស្រុកខ្លះទៀតថា អ្នកដែលកើតឆ្នាំ ត្រូវនឹងឆ្នាំបញ្ចុះសីមា ត្រូវចេញអោយផុតពីស្នូរធ្លាក់ ឫសសីមា បើមិនដូច្នោះទេ នឹងពានអាយុខ្លី ។

តាមទម្លាប់ខ្លះ ពេលកាត់ឫសសីមា មានតែអ្នកមានមុខងារក្នុងពិធីនោះទេ ដែលនៅជួយឧបត្ថម្ភ ឯអ្នកដទៃទៀតត្រូវថយចេញអស់រពើង ។

លុះកាត់ឫសសីមាស្រេចកាលណា គេទូងស្គរ ៣ ដងជាសញ្ញាដើម្បីហៅអ្នកដែលចេញឆ្ងាយ នោះអោយត្រឡប់ចូលមកវិញ ។ ពួក

www.budinst.gov.kh www.elibraryofcambodia.org

ឧបាសក ឧបាសិកា នាំគ្នាកាយដីលុប បូសសីមា រួចដាក់បញ្ឈរសន្លឹកសីមា លើកន្លែងរណ្ដៅនោះ ។

ប៉ុន្តែជំនឿជាទម្លាប់នេះ ក្រោយមកក៏ចេះតែបាត់បន្តិចម្ដងៗ អាស្រ័យដោយពុំមានហេតុផលច្បាស់លាស់និងមិនត្រូវតាមវិន័យផង ។

ចំណែកផ្ដៅ ឬ អំពោះដែលចងជាក្រឡាតារាង និងអំពោះឆៅចង បូសសីមានោះ អ្នកដែលបានចូលរួមហើយមានជំនឿដណ្ដើមគ្នាប្រញាយ ដើម្បីយកទៅធ្វើខ្សែចងក ចងចង្កេះអោយកូនចៅ ការពារខ្មោចបិសាច ។

បន្ទាប់មកទៀត គេរៀបចំពិធីឆ្លងបុណ្យ ដើម្បីផ្សាយបត្តិផល ។ ការផ្សាយបត្តិផលនេះ មិនមែនបានចំពោះតែអ្នកដែលបានចូលរួមក្នុងការកុសលនោះ គឺបានរហូតដល់ញាតិកាទាំង ៧ សន្ដាន របស់អ្នកធ្វើបុណ្យនោះផងទៀត ទោះជាធ្វើមរណកាលទៅហើយក្ដី នៅរស់នៅឡើយក្ដី ក៏ត្រូវបានទទួលនូវបុណ្យផលនោះទៅជាតិខាងមុខទាំងអស់គ្នា ។

***

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យសម្តេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម** អតីតក្រុមជំនុំព្រះត្រៃបិដក និងជាអគ្គាធិការនៃពុទ្ធិកសិក្សា ដែលព្រះអង្គធ្លាប់បានរៀបចំពិធីបញ្ចុះសីមានេះផ្ទាល់ជាមួយសម្តេចព្រះសង្ឃរាជ **ជួន ណាត** បានមានពុទ្ធដីកាថា « បុណ្យបញ្ចុះសីមានេះ ជាពិធីដ៏សំខាន់ក្នុងព្រះពុទ្ធសាសនា ព្រោះជាប់ទាក់ទងនឹងផ្លូវវិន័យជាពុទ្ធានុញ្ញាតនិងពុទ្ធប្បញ្ញត្តិ ។ ក្នុងការរៀបចំពិធីបញ្ចុះសីមានេះ ប្រការដែលត្រូវយកចិត្តទុកដាក់ជាសំខាន់នោះ គឺសង្ឃកម្មដែលសង្ឃត្រូវធ្វើ ។ ប្រសិនបើការរៀបចំពិធីបញ្ចុះសីមា ពុំបានត្រឹមត្រូវពេញលក្ខណៈទេ ព្រះវិហារនោះក៏ពុំអាចសំរេចទៅជាឧបោសថាគារត្រឹមត្រូវគួរ ដល់សង្ឃធ្វើសង្ឃកម្ម បានឧបោសថកម្មជាដើមបានដែរ ។ ព្រោះហេតុ នោះ ការរៀបចំពិធីបញ្ចុះសីមាត្រូវជ្រើសរើសភិក្ខុសង្ឃអង្គណាដែលមានបទពិសោធន៍ ឈ្លាសប្រតិភាណ ក្នុងរបៀបចាត់ចែងការងារសង្ឃ។ ការងារក្រៅពីនេះគឺជាការងារបន្ទាប់បន្សំ ដែលយើងតែងតែធ្វើតាមទំនៀមទំលាប់ ពីបុរាណមកដូចមានក្នុងឯកសារ ខាងដើមរួចហើយ ។

ពីបុរាណមកគេ ពិធីបញ្ចាន់តារាង គឺគេចងជាក្រឡា តារាងពីបួនជ្រុង ឬ ផ្កា ឬក៏រំពោះ តាមរបៀបភាគរបស់វត្តនីមួយៗ ។ ភូតនៃតារាងនីមួយ-

www.budinst.gov.kh www.elibraryofcambodia.org

តម្រូវទៅតាមហត្ថបាស ។ ការចងជាពារាងនេះ ក្នុងបំណងជៀសវាងក្រែងសង្ឃ បញ្ជាន់ពារាងទៅពុំបានត្រឹមត្រូវតាមហត្ថបាស ម្ល៉ោះហើយគេធ្វើជាពារាងដើម្បីជាខ្នាតកំណត់នៃហត្ថបាស សម្រាប់ភិក្ខុមួយអង្គៗ ឈរក្នុងពេលស្វូត្រ ញត្តិ ទុតិយកម្មវាចា ។

ប៉ុន្តែក្រោយមក សម្តេចព្រះសង្ឃរាជ **ជួន ណាត** ទ្រង់បានណែនាំអោយការរៀបចំបញ្ចុះសីមាដោយពុំចាំបាច់មានចងពារាងអំពីឫស្សីឬផ្តៅ ឬ ក៏អំពោះនាំអោយការចំណាយច្រើនផង ខាតពេលវេលាផង និងពលិពោធ ក្នុងការរៀបចំពិធីផង ។ សម្តេចព្រះសង្ឃរាជ **ជួន ណាត** ទ្រង់បានណែនាំ អោយភិក្ខុសង្ឃ ដែលត្រូវជាន់ពារាងយល់ពីហត្ថបាសហើយគោរពអោយ បានឲ្យច្បាស់ចត់ នៅពេលឈរជាន់ពារាង គឺថាភិក្ខុមួយអង្គៗ ត្រូវកំណត់ហត្ថ បាសដោយឈរអោបដៃ ដោយដាក់ប្រអប់ដៃទាំងពីរត្រង់ចុងដង្ហើម ក្លួយ ដៃទាំងសងខាងប៉ះគ្នាពីភិក្ខុមួយអង្គទៅមួយអង្គ ខាងមុខខាងក្រោយវាស់ពី ដងខ្លួន ទៅមុខមួយហត្ថ និង ទៅក្រោយមួយហត្ថ ។ នោះហើយ គឺជាខ្នាត នៃហត្ថបាស ។ ភិក្ខុមួយអង្គៗ ត្រូវហានស្មារតីភ្ជាក់

www.budinst.gov.kh www.elibraryofcambodia.org

រលើកដោយប្រុងប្រយ័ត្ន ក្នុងការបញ្ញាន់ ពារាងនេះគឺត្រូវប្រកាន់ខ្ជាប់នូវខ្នាតនៃហត្ថបាស ។

រីឯការបញ្ញាន់ពារាងត្រូវជាន់អោយសព្វដី ។ ប្រសិនបើព្រះវិហារនោះមានពីរជាន់ មានរបៀងចេញមកខាងក្រៅត្រឹមណា ភិក្ខុសង្ឃត្រូវធ្វើពិធីបញ្ញាន់ពារាងចេញមកខាងក្រៅត្រឹមនោះបន្ថែមទៀត ។ ចំណែកការសូត្រញត្តិទុតិយកម្មវាចា ក៏ត្រូវតែសូត្រអោយបានត្រឹមត្រូវ តាមក្បួនខ្នាតនៃអក្ខរវិធី ។ ធ្វើបានយ៉ាងនេះ ទើបពិធីបញ្ចុះសីមា មានលក្ខណៈត្រឹមត្រូវ។

សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុំ ស៊ុម** បានមានពុទ្ធដីកាបន្ថែមថា ពីបុរាណគេមានជំនឿណាស់ចំពោះបុណ្យបញ្ចុះសីមានេះ ។ ប្រជាជនខ្មែរ ប្រុស ស្រី ចាស់ ក្មេង បើឮថាមានវត្តណាធ្វើបុណ្យបញ្ចុះសីមា គេនាំគ្នាភ្លូកទឹកភ្លូកដី បររទេះគោ សាឡី ទៅចូលរួមអបអរសាទរ អនុមោទនាដោយក្តីសប្បាយរីករាយ ដេកនៅក្នុងវត្តនោះឯងរហូតដល់ចប់ពិធីបុណ្យ ។

ចំពោះដុំថ្មដែលជានិមិត្តសីមា គេនាំគ្នាលាបពនដោយទឹកមាស ស្រោះអំបោះឆៅរុំដោយ ហូល ផាមួងជាដើម ហើយប្រស់ព្រំដោយទឹកអប់ ។ រីឯរណ្តៅសីមាគេរៀបចំពិធីជីក ដោយមានខ្នាតមានបន្ទាត់ត្រឹម

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវ ។ គេទាំងឡាយនាំគ្នាយកវត្ថុផ្សេងៗ ទៅដាក់ក្នុងរណ្ដៅសីមា ពិសេស រណ្ដៅសីមាកិល តាមការចូលចិត្តហើយប្រាថ្នាបួងសួងទៅជាតិក្រោយ អោយបានសម្រេចតាមចិត្តខ្លួនប្រាថ្នា ។ ម្យ៉ាងទៀត រណ្ដៅសីមានោះ គេច្រើនរៀបចំជីកនៅព្រឹកថ្ងៃចូលបុណ្យ អោយហើយស្រេច ។ ប៉ុន្តែក្រោយបកវត្ថុដែលគេបង់ទៅក្នុងរណ្ដៅសីមា គេរៀបចំជាគណៈកម្មការមួយប្រមូលយកមកចាត់ចែងអោយកើតទៅជាប្រយោជន៍យ៉ាងសំខាន់សម្រាប់ព្រះសង្ឃប្រើប្រាស់ទៅវិញ ។ ធ្វើយ៉ាងនេះ ឈ្មោះថាបានញ៉ាំងផលទានរបស់អ្នកធ្វើ អោយរឹងរឹតតែមានផលអានិសង្សទ្វេឡើងថែមទៀត ។

ឯពេលវេលាកាត់ឫសសីមា គេធ្វើការគិតគូរ ជ្រើសរើសដោយល្អិតល្អន់ណាស់ ព្រោះគេមានជំនឿថាពេលវេលាកាត់ឫសសីមានោះ ហើយជាពេលមង្គលសំខាន់បំផុត ផ្ដល់ជោគជ័យជពារាសីពិសេសក្រៅពីបុណ្យកុសលផង ទាំងពួងដែលគេបានធ្វើ ។

សម្ដេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម** បានបញ្ជាក់ពីការជ្រើសរើសពេលវេលាថា តាមមតិរបស់ ហោរា **យក់** ដែលមានជំនាញខាងក្បួនហោរាសាស្ត្រថា ការជ្រើសរើសពេលវេលា គួរកំណត់ទៅតាមពណើរបស់

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃព្រោះថ្ងៃទាំង ៧ មានពណ៌ខុសគ្នា ។ ដើម្បីអោយដឹងថា ពេលថ្មីម៉ាន ចូលដល់ថ្ងៃអ្វី លោកអោយយកទឹកមួយផ្តិលទៅដាក់កណ្តាលវាលនៅពេល ព្រលឹមស្រាង ៗ ហើយនាំគ្នាពិនិត្យមើលទឹកនៅក្នុងផ្តិល បើឃើញទឹកនៅ ក្នុងផ្តិលមានពណ៌ក្រហមនោះហើយជាវេលាចូលថ្ងៃអាទិត្យ បើពណ៌លឿង ជាវេលាថ្ងៃច័ន្ទ បើពណ៌ស្វាយជាវេលាថ្ងៃអង្គារ បើពណ៌ស៊ីលៀប ជាវេលា ថ្ងៃពុធ បើពណ៌ត្រួយចេក បៃតងជាវេលាថ្ងៃព្រហស្បតិ៍ ពណ៌ខៀវជាវេលា ថ្ងៃសុក្រ បើពណ៌ព្រិងទុំជាវេលាថ្ងៃសៅរ៍ ។ បើម្ចាស់ដើមបុណ្យចង់កាត់ ឫសសីមានៅថ្ងៃណា ដែលគេជឿថាប្រកបដោយមង្គល ជោគជ័យ សេរី សួស្តី វិបុលសុខនោះ គេពិនិត្យមើលវេលាថ្ងៃតាមទឹក ដែលមានពណ៌នៅ ក្នុងផ្តិល នៅពេលព្រលឹមអរុណោទ័យ ហើយក៏កំណត់កាត់ឫសសីមា តាម ថ្ងៃនោះឯង ។

ដោយថ្ងៃមានពណ៌ខុសគ្នាដូច្នេះហើយ ទើបក្រុមពិធីការខាង សំលៀកបំពាក់ខ្មែរយើង គេកំណត់ការស្លៀកពាក់យកពណ៌តាមថ្ងៃទាំង ៧ រៀងរាបដរាបមកដល់សព្វថ្ងៃ ។ សឹងមានតែងជាពាក្យកាព្យឃ្លាយចាំថា ៖

www.budinst.gov.kh www.elibraryofcambodia.org

អាទិត្យក្រហមខ្ចី ឬ ចាស់ ច័ន្ទផ្លាស់លឿងទុំស្វាយអង្គារ
ថ្ងៃពុធស៊ីលៀបសមសោភា ព្រហស្បតិ៍ប្រែជាបៃតងត្រួយចេកខ្ចី ។
ពណ៌ខៀវក្រនៀវប្រើថ្ងៃសុក្រ ពណ៌និលព្រិលទុកសៅរ៍សេរី
តែងខ្លួនតាមក្បួនលោកស្រដី ចំរើនសុខសួស្តីជោគជ័យអើយ ។

ក្រោយកាត់បួសសីមារួចហើយ គេតែងប្រារព្ធពិធីដារ វេរភត្ត ប្រគេនព្រះសង្ឃ ជាកិច្ចឆ្លងបុណ្យ និង នៅពេលរសៀលគេនិមន្ត ធម្មកថិក ទេសនាសង្កាយនាត្រៃគ្របិ ជាការញ៉ាំងកុសលផលទានរបស់គេអោយកាន់តែរីកចំរើន ឡើងថែមទៀត ។

*ស្រាវជ្រាវដោយ :* **ជា តាន**

*ប្រធាននាយកដ្ឋានរដ្ឋបាល នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំ*
*បុណ្យជាតិ-អន្តរជាតិ*

www.budinst.gov.kh www.elibraryofcambodia.org

# អ្វីជាសីមា ?

នៅក្នុងឧបោសថក្ខន្ធកៈ មានសេចក្តីបញ្ជាក់ថា ក្នុងសម័យមួយនោះ ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់គង់នៅក្បែរភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ទ្រង់បានអនុញ្ញាតអោយភិក្ខុសង្ឃប្រជុំគ្នាសំដែងបាដិមោក្ខ ក្នុងថ្ងៃ ១៤ ឬ ១៥ ក្នុងមួយបក្សម្តង « ក្នុងសុក្កបក្ស គឺខាងខ្នើតម្តង និងក្នុងកាឡបក្ស គឺខាងរនោចម្តង » ។ ពេលនោះពួក ឆព្វគ្គិយភិក្ខុ សំដែងបាដិមោក្ខតាមបរិស័ទរបស់ខ្លួន ។ ព្រះមានព្រះភាគទ្រង់ជ្រាប បញ្ហានេះហើយ ក៏ទ្រង់បញ្ញត្តិថា ភិក្ខុមិនត្រូវសំដែងបាដិមោក្ខតាមបរិស័ទរបស់ខ្លួនទេ ។ ភិក្ខុណាសំដែងភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ បន្ទាប់មកព្រះអង្គទ្រង់អនុញ្ញាតនូវ ឧបោសថកម្មដល់ពួកភិក្ខុដែលព្រមព្រៀងគ្នា ។ ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យថា ព្រះអង្គអនុញ្ញាតនូវឧបោសថកម្មដល់ពួកភិក្ខុដែលព្រមព្រៀង នោះមិនដឹងជាព្រមព្រៀងត្រឹមណាព្រមព្រៀងតែក្នុងអាវាសមួយ ឬ ក៏ព្រមព្រៀង លើផែនដីទាំងមូល ? ភិក្ខុទាំងឡាយក៏ទៅក្រាបបង្គំទូលសួរព្រះដ៏មាន ព្រះភាគទើបព្រះអង្គទ្រង់អនុញ្ញាតថា ការព្រមព្រៀងនោះព្រមព្រៀងតែក្នុងអាវាស

www.budinst.gov.kh www.elibraryofcambodia.org

មួយៗ ប៉ុណ្ណោះទេ ។ ភិក្ខុទាំងឡាយក៏កើតមានសេចក្តីសង្ស័យទៀតថា ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតថា ព្រមព្រៀងគ្នាតែក្នុងអាវាសមួយប៉ុណ្ណោះទេ ។ រីឯអាវាសមួយ នោះទៀតសោត ក៏មិនដឹងជាកំរិតត្រឹមណា ? និមិត្តតែមានសេចក្តី ឆើងឆ្ងល់យ៉ាងនេះ ភិក្ខុទាំងឡាយក្រាបបង្គំទូលសួរ ព្រះសម្ពុទ្ធម្តងទៀត ។ ទើបព្រះមានព្រះភាគ ទ្រង់អនុញ្ញាតអោយសន្មតសីមា ដើម្បីអោយមានទីកំណត់សម្រាប់ធ្វើសង្ឃកម្ម មានឧបោសថកម្មជាដើម ដោយសេចក្តីព្រមព្រៀងយកសីមា នោះជាទីកំណត់ អោយដឹងនូវទីអាវាសរបស់សង្ឃមួយៗថា « **អនុជានាមិ ភិក្ខវេ សីមំ សម្មន្និតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអោយភិក្ខុសង្ឃសន្មតនូវសីមា » ។

## អ្វីជាសីមា ?

សីមាគឺការកំណត់ទីតាំងណាមួយធ្វើជាព្រំដែន ខ័ណ្ឌរបង សម្រាប់សង្ឃធ្វើសង្ឃកម្មផ្សេងៗ មានឧបោសថកម្មជាដើម អាស្រ័យដោយការយកនូវនិមិត្តទាំង ៨ មានបព្វតនិមិត្តជាដើម និមិត្តណាមួយមកធ្វើជាការកំណត់ ឈ្មោះថាសីមា ។

www.budinst.gov.kh www.elibraryofcambodia.org

*សីមាមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?*

**សីមា ច នាមេសា ពទ្ធសីមា អពទ្ធសីមា ចាតិ ទុវិធោ ហោតិ**

សីមាមានពីរយ៉ាងគឺ **ពទ្ធសីមា ១ និង អពទ្ធសីមា ១ ។**

*ដូចម្ដេចដែលហៅថាពទ្ធសីមា ?*

**តត្ថ ឯកាទសវិបត្តិសីមាយោ អតិក្កមិត្វា តិវិធសម្បត្តិយុត្តា និមិត្តេន និមិត្តំ ពន្ធិត្វា ធម្មតា សីមា ពទ្ធសីមា នាម ។**

បណ្ដាសីមាទាំងពីរប្រការនោះ សីមាណាដែលប្រាសចាក នូវសីមាវិបត្តិទាំង ១១ ប្រការ និងប្រកបដោយសម្បត្តិទាំងបីយ៉ាង ហើយលោកចងនូវនិមិត្តដោយនិមិត្ត ( មានបព្វតនិមិត្តជាដើម ) រួចហើយសន្មត សីមានោះឈ្មោះថា ពទ្ធសីមា « គឺសីមាដែលសង្ឃបានសូត្រចង » ។

www.budinst.gov.kh www.elibraryofcambodia.org

## ដូចម្តេចដែលហៅថាអពទ្ធសីមា ?

**អពទ្ធសីមា មាន គាមសីមា សត្តព្ភន្តរសីមា ឧទកុក្ខេបសីមាតិ តិវិធា ។**

អពទ្ធសីមា ( សីមាដែលសង្ឃមិនបានសូត្រចង ) មានបីប្រការគឺ :

**គាមសីមា ១ សត្តព្ភន្តរសីមា ១ និងឧទកុក្ខេបសីមា ១ ។**

**វិបត្តិសីមា ១១ យ៉ាង**

**១- អតិខុទ្ទកា** សីមាតូចពេក ។ សីមាតូចពេកបានន័យថា សីមាណាដែលភិក្ខុ ២១ រូបមិនអាចអង្គុយប្រជុំគ្នាធ្វើសង្ឃកម្មបាន សីមានោះឈ្មោះថា សីមាតូចពេក ។

**២- អតិមហាតី** សីមាធំពេក ។ សីមាណាដែលភិក្ខុសន្មតអោយធំហួសពី ៣យោជន៍ សូម្បីត្រឹមតែមួយចំរៀកសក់ សីមានោះឈ្មោះថា សីមាធំពេក ។

www.budinst.gov.kh www.elibraryofcambodia.org

៣. **ខណ្ឌនិមិត្តា** សីមាណាដែលមាននិមិត្តមិនជាប់គ្នាហៅថា ខណ្ឌនិមិត្ត និមិត្តដាច់ ។ ក្នុងន័យថា កំណត់និមិត្តទិសខាងកើតរួចហើយ ក៏កំណត់និមិត្តក្នុងទិសជាបន្តបន្ទាប់ទៅដល់ទិសខាងជើង ឬទិសណាមួយក៏ឈប់នៅទិសនោះទៅ មិនបានកំណត់និមិត្តទិសខាងកើតត្រូតថែមម្តងទៀត ។ ពុំនោះសោតទេ យករបស់ណាមួយដែលមិនគួរនឹងធ្វើជានិមិត្តបាន មានដើមដូង ត្នោត ឬ ដង្កត់ឈើណាមួយ ជាដើមធ្វើជានិមិត្ត ។

៤. **ឆាយានិមិត្តា** យកស្រមោលធ្វើជានិមិត្ត ។ គឺភិក្ខុសន្មតសីមាដោយយកស្រមោលណាមួយមានស្រមោលភ្នំជាដើម ធ្វើជានិមិត្ត ។

៥. **អនិមិត្តា** ឥតមានអ្វីជានិមិត្ត ។ គឺជាភិក្ខុសន្មតសីមា ដោយឥតមានយកអ្វីធ្វើជានិមិត្តទាំងអស់ ។

៦. **ពហិ សីមេ ឋិតសម្មតា** សីមាដែលភិក្ខុសង្ឃឈរក្រៅសីមដ្ឋាន គឺសីមាដែលភិក្ខុសង្ឃកំណត់និមិត្តដោយឈរក្រៅសីមដ្ឋាន ហើយសន្មតនិមិត្ត ។

៧. **នទិយា សន្មតា** សីមាដែលភិក្ខុសន្មតក្នុងស្ទឹង

www.budinst.gov.kh www.elibraryofcambodia.org

៨. **សមុទ្ទេ សម្មតា** សីមាដែលភិក្ខុសន្មតក្នុងសមុទ្រ

៩. **ជាតស្សរេ សម្មតា** សីមាដែលភិក្ខុសន្មតក្នុងជាតស្រះ គឺស្រះកើតឯង ឥតមានអ្នកណាជីក ។

**សាហិ ឯទំ សម្មតាបិ សព្វា ភិក្ខវេ នទី អសីមា សព្វោ សមុទ្ទោ អសីមោ សព្វោ ជាតស្សរោ អសីមោតិ វចនតោ អសម្មតា វ ហោតិ** ។ តាមពិត សីមាវិបត្តិទាំង ៣នោះ ( គឺ ស្ទឹងសមុទ្រជាតស្រះ ) ទុកជាភិក្ខុសន្មតបែបនេះក៏ដោយ ក៏ឈ្មោះថាមិនសន្មត ដោយពិតព្រោះដីកាថា ម្នាលភិក្ខុទាំងឡាយ ស្ទឹងទាំងអស់មិនមែនជាសីមាទេ សមុទ្រទាំងអស់មិនមែនជាសីមាទេ ជាតស្រះទាំងអស់មិនមែនជាសីមាទេ ។

១០. **សីមាយ សីមំ សម្ភិន្ទន្តេន សម្មតា** សីមាដែលភិក្ខុសន្មតទម្លុះទំលាយសីមាចាស់របស់ភិក្ខុដទៃ គឺសន្មតសីមារបស់ខ្លួនអោយប៉ះជាប់ទៅនឹងសីមាដទៃ ឬអោយគ្របទៅក្នុងសីមាដទៃ តាំងពីមួយចំរៀកសក់ឡើងទៅ រហូតដល់ទីដែលភិក្ខុបួនរូបអង្គុយមិនបាន ។

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



១១. **សីមាយសីមំ អជ្ឈោត្ថរន្តេន សម្មតា** សីមាដែលភិក្ខុសន្មតគ្របសង្កត់នូវសីមាដោយសីមាគឺសន្មតជាន់គ្របជ្រុលទៅក្នុងពទ្ធសីមារបស់ភិក្ខុដទៃតាំងពីចំនួនទីប្រមាណភិក្ខុ ៤ រូបអង្គុយល្មមឡើងទៅ ឬ ធ្វើអោយគ្របទៅក្នុងពទ្ធសីមារបស់ភិក្ខុដទៃទាំងមូល ។

## សម្បត្តិ ៣ យ៉ាង

១. **និមិត្តសម្បត្តិ** គ្រប់គ្រាន់ដោយនិមិត្ត

២. **បរិសសម្បត្តិ** គ្រប់គ្រាន់ដោយបរិស័ទ

៣. **កម្មវាចាសម្បត្តិ** គ្រប់គ្រាន់ដោយកម្មវាចា

## និមិត្តសម្បត្តិ

និមិត្តសម្បត្តិ នោះមាន ៨ យ៉ាងគឺ :

១. **បព្វតនិមិត្តំ** យកភ្នំធ្វើជានិមិត្ត ។ ភ្នំមានបីយ៉ាងគឺ ភ្នំដីសុទ្ធ ១ ភ្នំថ្មសុទ្ធ ១ ភ្នំមានដីនិងថ្មលាយគ្នា ១ ។ ទំហំភ្នំនោះ តាំងពីប៉ុនរូបដំរីឡើង

www.budinst.gov.kh www.elibraryofcambodia.org

ទៅរហូតដល់ប៉ុនភ្នំសិនេរុ គួរយកធ្វើជានិមិត្តបាន បើតូចជាងរូបដីរ ឬធំជាង ប៉ុន្តែ ជាគំនរខ្សាច់ទទេនោះ ក៏មិនគួរនឹងយកធ្វើជានិមិត្តបាន ឡើយ ។

២. **បាសាណនិមិត្តំ** យកថ្មធ្វើជានិមិត្ត ។ ទំហំថ្មនោះយ៉ាងតូច បំផុតប៉ុនដុំស្ករ អំពៅដែលគេថ្លឹងបានចំនួន ៣២ បល្លៈ គឺ ៦៤ នាឡិយើង សព្វថ្ងៃនេះ បើតូចជាងនោះ មិនគួរយកធ្វើជានិមិត្តទេ តែបើធំឡើងទៅ ប៉ុនរូបគោឬ ក្របីយ៉ាងធំក៏គួរប៉ុន្តែ បើធំជាងនោះទៅទៀត ក៏មិនគួរដែរ ហើយយកដុំឥដ្ឋធំប៉ុនានក្តី ឬដុំថ្មតូច ៗ ដែលមិនគួរធ្វើជានិមិត្តបានយកមក ប្រមូលគ្នាជាគំនរអោយធំឡើងក្តី ក៏មិនគួរយកធ្វើជានិមិត្តបានដែរ ។

៣. **វននិមិត្តំ** យកព្រៃធ្វើជានិមិត្ត ។ ព្រៃនោះ បើមានសុទ្ធតែ ស្មៅ ឬដើមឈើ ដែលមានសំបកខាងក្រៅជាខ្លឹម មានដើមត្នោត និងដើម ដូចជាដើមក៏មិនគួរនឹងយកធ្វើជានិមិត្តបានឡើយ ។ បើព្រៃនោះមានពួក ដើមឈើដែលមានខ្លឹមខាងក្នុងមានដើមរាំងជាដើមយ៉ាងតិចបំផុតត្រឹម ៤ ឬ ៥ ដើម ទើបគេយកធ្វើជានិមិត្តបាន ។

www.budinst.gov.kh www.elibraryofcambodia.org

៤. **រុក្ខនិមិត្តំ** យកឈើធ្វើជានិមិត្ត ។ ឈើនោះបើមានសម្បក ក្រៅជាខ្លឹមមានដើម ត្នោត និងដើមដូងជាដើម ក៏មិនគួរធ្វើជានិមិត្តបានឡើយ បើដើមឈើនោះមានខ្លឹមខាងក្នុង ហើយជាឈើរស់នៅលើផែនដី ទើបគួរធ្វើជានិមិត្តបាន ។

៥. **មគ្គនិមិត្តំ** យកផ្លូវជានិមិត្ត ។ ផ្លូវនោះបើខ្លីៗ តូចៗ មានផ្លូវដើរចូលទៅព្រៃនឹងទៅទីស្រែជាដើម ក៏មិនគួរនឹងយកធ្វើជានិមិត្តបានឡើយ ។ បើផ្លូវវែងៗហើយជា ផ្លូវគេតែងដើរដោយជើងជាប្រក្រតី ផ្លូវគេតែងបររទេះទៅមកជាប្រក្រតីនោះ ទើបគួរធ្វើជានិមិត្តបាន ។

៦. **វម្មិកនិមិត្តំ** យកដំបូកជានិមិត្ត ។ កំពស់ និងទំហំដំបូកនោះបើយ៉ាងទាបបំផុតកំពស់ត្រឹម ៨ ធ្នាប់ ទំហំប៉ុនស្នែងគោប៉ុណ្ណោះ ល្មមធ្វើជានិមិត្តបាន បើទាបតូចជាងនោះមិនគួរនឹងធ្វើជានិមិត្តបានឡើយ ។

៧. **នទី និមិត្តំ** យកស្ទឹង ឬ ទន្លេជានិមិត្ត ។ គឺស្ទឹង ឬ ទន្លេដែលទឹកហូរមិនដាច់ ពុំនោះទីណាមួយក្នុងវស្សានរដូវ ទឹកភ្លៀងធ្លាក់ចុះរឿយៗ មានខ្សែទឹកហូរមិនដាច់ទីនោះក៏ហៅថានទីបាន ។ ព្រះអដ្ឋកថាចារ្យ សំដែងពីលក្ខណៈនៃនទីនោះថា « ក្នុង វស្សានរដូវ ៤ ខែ ទីណាមួយមានខ្សែទឹក

www.budinst.gov.kh www.elibraryofcambodia.org

ហូរមិនដាច់ ទឹកនោះមានជំរៅល្មមទឹកដល់ស្មងរបស់នាងភិក្ខុនីដែលស្លៀកបរិមណ្ឌលហើយដើរឆ្លងទៅ ទីនោះក៏ហៅថា នទីបាន » ទីប៉ុណ្ណោះគួរធ្វើជានិមិត្តបាន ។

៨. **ឧទកនិមិត្តំ** យកទឹកជានិមិត្ត ។ ទឹកនោះបើយកទៅដាក់ក្នុងវត្ថុណាមួយ មាន ទូក ឬ ពាង អាង ជាដើម នោះមិនគួរនឹងកំណត់ធ្វើជានិមិត្តបានឡើយ ។ ឯទឹកនោះ ចំពោះយកទឹកដែលដាក់នៅផ្ទាល់លើផែនដី គឺទឹកមិនហូរ ដែលដក់ក្នុងទីទាំងឡាយ មានរណ្ដៅស្រះបោក្ខរណី ជាតស្រះ និងលោណមហាសមុទ្រជាដើម ទឹកយ៉ាងនេះ គួរកំណត់ធ្វើជានិមិត្តបាន ។

ម៉្យាងទៀត « បើទីនោះមិនមានដក់ទឹកទេ » គប្បីជីកផែនដីធ្វើជារណ្ដៅហើយដងទឹកមកដាក់អោយពេញក្នុងរណ្ដៅនោះ ទឹកនោះឯង កាលណា លោកសូត្រកម្មវាចាចប់ទៅ ក៏ដក់សល់នៅខ្លះ ទើបឡើងពេញជានិមិត្តបាន ។ កាលណាបើទឹករីងអស់ទៅ ក៏គប្បីយកគំនរថ្ម ឬ គំនរខ្សាច់មកដាក់ត្រង់ទីនោះ ពុំនោះទេ ដាំសសរឈើក្នុងទីនោះក៏បាន ដើម្បីធ្វើជាគ្រឿងសំគាល់ថាជា និមិត្ត ។

www.budinst.gov.kh www.elibraryofcambodia.org

## បរិសសម្បត្តិ

បរិសសម្បត្តិនោះ គឺបរិបូណ៌ដោយភិក្ខុជាបរិស័ទ គឺភិក្ខុយ៉ាងតិចបំផុតត្រឹម ៤ រូប និងមានចំនួនយ៉ាងច្រើនឡើងទៅមិនកំណត់ ប្រជុំព្រមគ្នាក្នុងសីមា ហើយសន្មតសីមា យ៉ាងនេះឈ្មោះថា បរិសសម្បត្តិ ។

## កម្មវាចាសម្បត្តិ

កម្មវាចាសម្បត្តិនោះ គឺបរិបូណ៌ដោយកម្មវាចា គឺថា ភិក្ខុជាអ្នកឈ្លាសស្វាត្រសន្មតសីមាដោយញត្តិទុតិយកម្មវាចាថា « **សុណាតុ មេ ភន្តេ សង្ឃោ ។ល។ ឯវមេតំ ធារយាមិ** » ដោយត្រឹមត្រូវតាមឋានករណៈនៃអក្ខរៈនិងប្រភេទនៃអក្ខរៈ មានមិនច្រឡំ សិថិលទៅជាធនិត១ មកជាសិថិលជាដើម ។ យ៉ាងនេះឈ្មោះថា កម្មវាចាសម្បត្តិ ។

សីមាដែលផុតចាកសីមាវិបត្តិ ១១ យ៉ាង និងប្រកបដោយសម្បត្តិទាំង ៣ យ៉ាង ដូចបានពោលមកហើយនេះ ឈ្មោះថា ពទ្ធសីមា ។ ពទ្ធសីមានេះមាន ៣ យ៉ាងគឺ : សមានសំវាសសីមា ១ អវិប្បវាសសីមា ១ និងខណ្ឌសីមា ១ ។

www.budinst.gov.kh www.elibraryofcambodia.org

**សមានសំវាសសីមា** គឺសីមាមានសំវាសស្មើគ្នា ជាដែនសម្រាប់សង្ឃធ្វើ សង្ឃកម្ម ដោយព្រមព្រៀងគ្នា ។

**អវិប្បវាសសីមា** គឺសីមាដែលសង្ឃសន្មតសង្កត់ត្រួតពីលើ សមានសំវាសសីមា ដោយញត្តិទុតិយកម្មវាចា ដទៃពីសមានសំវាសសីមា ដើម្បីភិក្ខុសង្ឃនឹងនៅប្រាសចាកតែចីវរបាន ។

**ខណ្ឌសីមា** គឺសីមាតូច ដែលសង្ឃសន្មតទុកខាងក្នុងពទ្ធសីមាធំ « ក្នុងមហាសីមា » ដើម្បីនឹងធ្វើសង្ឃកម្មទាំងឡាយ មានឧបសម្បទាកម្មជាដើម គឺថាមិនរង្កៀសដោយភិក្ខុដទៃ ដែលនឹងចូលមកក្នុងសីមានោះ ។

ខណ្ឌសីមានោះ គឺសីមាដែលយើងធ្វើក្នុងស្រុកខ្មែរយើងសព្វថ្ងៃនេះបានសន្មតទីរោងឧបោសថទាំងមូលអោយជាខណ្ឌសីមា ។ ឯទំហំខណ្ឌសីមានោះបើយ៉ាងតូចបំផុតត្រឹមភិក្ខុចំនួន ២១ រូបអង្គុយល្មម បើតូចជាងនោះមិនគួរ តែបើធំឡើងទៅដល់ភិក្ខុចំនួន ១០០ រូបអង្គុយល្មមក៏គួរ ។ ឯវិធីដែលនឹងសូត្រសន្មតសីមានោះ គឺត្រូវសន្មតជាសមានសំវាសសីមាមុនហើយសឹមសន្មតអវិប្បវាសសីមាជាខាងក្រោយ ដូចជាវិធីដែលសន្មតមហាសីមានោះដែរ ។ ព្រោះហេតុនោះហើយបានជា នៅពេលដែលនឹងសូត្រដក

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវសូត្រដកអវិប្បវាសសិមាមុន ហើយសឹមសូត្រដកសមានសំវាសសិមាជាខាងក្រោយ ព្រោះអវិប្បវាសសិមា ឋិតនៅខាងលើនៃសមានសំវាសសិមា។

ឯកិច្ចដែលនឹងសូត្រដកសិមានោះ ព្រោះអាស្រ័យហេតុពីរ យ៉ាងគឺ :

១. សិមាតូច សង្ឃចង់ធ្វើសីមានោះអោយធំចំរើនជាងមុន ទើបសូត្រដកសិមាតូចនោះចេញហើយសន្មតជាថ្មីឡើង ។

២.សិមាធំ សង្ឃចង់ធ្វើសិមានោះអោយតូចទៅវិញ ប្រយោជន៍នឹងអោយមានឱកាសដល់វិហារនៃភិក្ខុវត្តឯទៀត ទើបសូត្រដកសិមាធំនោះចេញ ហើយសន្មតជាថ្មីឡើង ។

ឯពទ្ធសិមានេះ ដែលសង្ឃបានសន្មតហើយស្រេចជាមហាសិមាក្តី ខណ្ឌសិមាក្តី សិមាទាំងនេះដែលនឹងត្រឡប់ទៅជាទីទទេ មិនមែនជាទីសិមាទៅវិញនោះដោយហេតុពីរយ៉ាងគឺ : ដោយសង្ឃត្រូវការសូត្រដកសិមានោះដោយញត្តិទុតិយកម្មវាចា ១ ដោយផុតអស់ព្រះពុទ្ធសាសនា ១ ។

www.budinst.gov.kh www.elibraryofcambodia.org

## អពទ្ធសីមា

សីមាដែលសង្ឃមិនបានសូត្រចង មិនបានសន្មត ឈ្មោះថា អពទ្ធសីមា មាន ៣ យ៉ាងគឺ : **គាមសីមា ១ សត្តព្ភន្តរសីមា ១ ឧទកុក្ខេបសីមា ១** ។

## គាមសីមា

ទីជាគាមក្ខេត្ត គឺទីស្រុកមួយៗ និគមមួយៗ ឈ្មោះថាគាមសីមាៗ នេះព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតដល់ភិក្ខុ ជាគាមវាសីទាំងឡាយ គឺភិក្ខុដែលអាស្រ័យនៅក្នុងស្រុកជាប្រក្រតីថា **អសម្មតាយ ភិក្ខវេ សីមាយ អដ្ឋបិតាយ យំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ យា គាមស្ស វា គាមសីមា និគមស្ស វា និគមសីមា អយំ តត្ថ សមានសំវាសា ឯកុបោសថា** «សេចក្តីថា» ម្នាលភិក្ខុ ទាំងឡាយកាលបើសីមាសង្ឃមិនទាន់បានសន្មត មិន ទាន់បានតាំងទុក ហើយភិក្ខុចូលទៅអាស្រ័យនៅក្នុងស្រុកនិង និគម ឯណាមួយ ទីដែននៃស្រុក និងនិគមនោះ មានទំហំធំតូចប៉ុន្មាន ទីដែន

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុណ្ណោះ ជាសីមាទាំងអស់ មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ។ ក្នុងអដ្ឋកថា ថា « **គាម** » ស័ព្ទនេះប្រែថា « ស្រុក » ត្រូវសង្គ្រោះយក « **នគរ** » ស័ព្ទដែលប្រែថា « ទីក្រុង » បញ្ចូលក្នុងគាមស័ព្ទនេះផង ។ អាស្រ័យហេតុនេះ ទីក្រុងក្តី ស្រុកក្តី និគមក្តី ឈ្មោះថា គាមសីមាទាំងអស់។ ម្យ៉ាងទៀត បើបរមក្សត្រ ស្តេចបានកំណត់ទីភូមិប្រទេសណាមួយ ក្នុងគាមក្ខេត្តឯណាមួយថា « ទី នេះចូលជាវិសុំគាម » ស្រុកផ្សេងចុះ ហើយបានព្រះរាជទានផ្តាច់ដល់អ្នក ណាមួយ ទីភូមិប្រទេសនោះឈ្មោះថាវិសុំគាមសីមា ។ ព្រោះហេតុនោះ វិសុំគាមសីមា ទីសីមាដទៃ គឺគាមសីមា នគរសីមា និគមសីមាក្តី ក៏អាច សំរេចនូវសង្ឃកម្មទាំងពួង មានឧបសម្បទាកម្ម និងឧបោសថកម្ម ជាដើម ដល់ភិក្ខុសង្ឃបាន ដូចជាពទ្ធសីមាដែរ ប៉ុន្តែ មិនអាចនឹងរក្សានូវ តិចីវរា វិប្បវាស គឺមិនអាចនឹងនៅប្រាស់ចាកត្រៃចីវរអោយឆ្ងាយពីហត្ថបាសក្នុង គាមសីមានោះបានឡើយ គាមសីមាប្លែកគ្នានឹងពទ្ធសីមាតែប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

## សត្តព្ភន្តរសីមា

ក្នុងទីព្រៃសុទ្ធមិនមានស្រុក ក្នុងរវាង ៧ អព្ភន្តរៈ ដោយជុំវិញ ឈ្មោះថា សត្តព្ភន្តរសីមា ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតដល់ភិក្ខុជាវនវាសីទាំងឡាយ គឺ ភិក្ខុដែលអាស្រ័យនៅក្នុងព្រៃជាប្រក្រតី ថា « **អគាមកេ ភិក្ខវេ អរញ្ញេ សមន្តា សត្តព្ភន្តរា អយំ តត្ថ សមានសំវាសា ឯកុបោសថា** « សេចក្តីថា » ម្នាលភិក្ខុទាំងឡាយ ទី ៧ អព្ភន្តរៈ ដោយជុំវិញ ក្នុងព្រៃមិនមានស្រុកទីប៉ុណ្ណោះ ជាទីមានសំវាសស្មើគ្នា មានឧបោសថ ជាមួយគ្នា ។ ក្នុងអដ្ឋកថា ថាអព្ភន្តរៈមួយៗនោះមានប្រវែង ២៨ ហត្ថ ឯទី ៧ អព្ភន្តរៈដោយជុំវិញនោះ គឺវាស់អំពីភិក្ខុដែលអង្គុយនៅ ក្នុងទីបំផុតភិក្ខុ ជាបរិស័ទទាំងពួង ចេញទៅគ្រប់ៗទិសដោយជុំវិញ ព្រោះហេតុនោះឯង សីមា នោះដែលនឹងចំរើនធំឡើង ក៏ចំរើនធំឡើងដោយអំណាចភិក្ខុដែលជាបរិស័ទមានច្រើនដែលនឹងថយតូចចុះទៅក៏ថយតូចចុះដោយអំណាចភិក្ខុជាបរិស័ទមានតិច ។

សត្តព្ភន្តរសីមានេះ បានឈ្មោះថា តិចិវរាវិប្បវាសផង ព្រោះអាចនឹងនៅប្រាសចាកត្រៃចីវរបាន ក្នុងចន្លោះទី ៧ អព្ភន្តរៈដោយជុំវិញ តែថា

www.budinst.gov.kh www.elibraryofcambodia.org

កាលេនឹងនៅប្រាសចាកតែចីវរ ដែលទុកក្នុងរវាងទី ៧ អព្ភន្តរៈបាននោះ អោយវាស់អំពីភិក្ខុជាម្ចាស់របស់ចេញទៅ ក្នុងទិសមួយៗ ៧ អព្ភន្តរៈ ដោយជុំវិញផ្សេងៗគ្នា បើវាស់កាត់ត្រង់អំពីទិសម្ខាងទៅម្ខាងនោះបាន ១៤ អព្ភន្តរៈគ្រប់ៗរូប បើបែរជាទុកចីវរអោយផុតអំពីទី ៧ អព្ភន្តរៈ ដោយជុំវិញខ្លួននោះទៅលុះអរុណរះឡើង ចីវរនោះ ជានិស្សគ្គិយ ភិក្ខុជាម្ចាស់ចីវរ ត្រូវអាបត្តិបាចិត្តិយ ព្រោះហេតុនោះ បានជាត្រូវវាស់ទី ៧ អព្ភន្តរៈ ដោយជុំវិញចំពោះភិក្ខុមួយរូបៗ ។ ឯការដែលអោយវាស់អំពីភិក្ខុជាទីបំផុតនៃបរិស័ទចេញទៅនោះ ចំពោះតែសីមា ដែលសង្ឃធ្វើសង្ឃកម្មទាំងពួងនោះទេ ។ បើសង្ឃពីរពួក នឹងធ្វើវិន័យកម្មផ្សេងៗគ្នា ដោយអព្ភន្តរៈសីមា ក្នុងព្រៃជិតគ្នានោះ គប្បីទុកទីទទេចំនួន ៧ អព្ភន្តរៈជាសីមន្តរិក[១] ក្នុងចន្លោះពាក្យពន្ទរសីមា ទាំងពីរនោះ ដើម្បីកុំអោយមានសេចក្តីរង្កៀសដល់សីមាទាំងពីរនោះឯង ។

(១) សីមន្តរិក « ទីជាចន្លោះនៃសីមា » គឺទីដីទំនេរ មិនមែនជាសីមាដែលសង្ឃទុកអោយរាំងសីមាមិនអោយប៉ះគ្នា ។

## ឧទកុក្ខេបសីមា

ក្នុងនទី គឺស្ទឹង ឬ ទន្លេសមុទ្រ និងជាតស្រះ ក្នុងរវាងទីដែលសាចទឹក ឈ្មោះថា ឧទុកក្ខេបសីមា ។ ទីទាំងឡាយមានស្ទឹងជាដើមនោះ កាលពីដើមដំបូង ព្រះសម្មាសម្ពុទ្ធទ្រង់ហាមមិនអោយធ្វើពទ្ធសីមាទេ ដោយពុទ្ធដីកាថា « **សព្វា ភិក្ខវេ នទី អសីមា សព្វោ សមុទ្ទោ អសីមោ សព្វោ ជាតស្សរោ អសីមោ** » « សេចក្តីថា » ម្នាលភិក្ខុទាំងឡាយ នទី គឺស្ទឹង ឬ ទន្លេ ទាំងអស់ មិនមែនជាទីសីមាទេ « បើទុកជាសមុទ្ទ ក៏ឈ្មោះថាពិតមែនសមុទ្ទ គឺមិនឡើងជាសីមាឡើយ » ។ លុះដល់មកខាងក្រោយ ទើបព្រះអង្គ អនុញ្ញាតឧទកុក្ខេបសីមា ក្នុងទីទាំងឡាយមានស្ទឹងជា ដើមនោះថា **នទិយា វា ភិក្ខវេ សមុទ្ទេ វា ជាតស្សរេ វា យំ មជ្ឈិមស្ស បុរិសស្ស សមន្តា ឧទកុក្ខេបា អយំ តត្ថ សមានសំវាសា ឯកុបោសថា** « សេចក្តីថា » ម្នាលភិក្ខុទាំងឡាយ ទីឯណាក្នុងស្ទឹង ឬ ទន្លេ ក្នុងសមុទ្រ ក្នុងជាតស្រះ ទីនោះកំណត់ត្រឹមខាងក្នុងរវាងទីដែលសាចទឹកនៃ មជ្ឈិមបុរសដោយជុំវិញ នេះឈ្មោះថា សីមាមានសំវាសស្មើគ្នាមានឧបោសថ ជាមួយគ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

## បាលីវេរដុំថ្មជានិមិត្តសីមា

ឱកាស មយំ ភន្តេ ឥមេ មហន្តេ បាសាណបិណ្ឌេ សីមាយ និមិត្តករណត្ថាយ ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមេ បាសាណបិណ្ឌេ បដិគ្គណ្ហាតុ បដិគ្គហិត្វាន ឥមេហិ បាសាណបិណ្ឌេហិ និមិត្តំ កិត្តេត្វា ខណ្ឌសីមំ សម្មន្នតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

សូមគោរព បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយសូមវេរនូវដុំថ្មធំៗ ទាំងឡាយនេះ ប្រគេនចំពោះព្រះសង្ឃ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើជានិមិត្តសីមា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវដុំថ្មទាំងឡាយនេះ ហើយសន្មតនូវខ័ណ្ឌសីមាចុះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

www.budinst.gov.kh www.elibraryofcambodia.org

# បាលីវេរវោងឧបោសថ

មយំ ភន្តេ ឥមំ ( ឧបោសថាគារំ ) ភារេក្ខ ឧបោសថប្បវារណាទិកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុ-សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ ( ឧបោសថាគារំ ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ ...តតិយម្បិ ...។

បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយបានចាត់ចែងធ្វើនូវ ( រោងសម្រាប់ធ្វើឧបោសថ ) នេះ ហើយសូមវេរប្រគេន ដល់ព្រះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្ម និងបវារណាកម្មជាដើម បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួលយក នូវរោងសម្រាប់ធ្វើឧបោសថនេះ ដើម្បីសេចក្តីចំរើនដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែង ទៅហោង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង។

***

www.budinst.gov.kh www.elibraryofcambodia.org

## បាលីសូធ្យដកតិចីវរាវិប្បវាស

**សុណាតុ មេ ភន្តេ សង្ឃោ យោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ សម្មតោ , យទិ សង្ឃស្ស បត្តកល្លំ , សង្ឃោ តំ តិចីវរេន អវិប្បវាសំ សមូហនេយ្យ , ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ , យោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ សម្មតោ សង្ឃោ តំ តិចីវរេន អវិប្បវាសំ សមូហនតិ , យស្សាយស្មតោ ខមតិ , ឯតស្ស តិចីវរេន អវិប្បវាសស្ស សមុគ្ឃាតោ , សោ តុណ្ហស្ស , យស្ស នក្ខមតិ , សោ ភាសេយ្យ ។ សមូហតោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ , ខមតិ សង្ឃស្ស , តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។**

« ពាក្យប្រែ » បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យរបស់ខ្ញុំ ភូមិប្រទេសឯណា ដែលសង្ឃសន្មតហើយ អោយជាដែនមិននៅប្រាសចាកត្រៃចីវរ បើសង្ឃកម្មនេះ មានកាលដ៏សមគួរហើយ សង្ឃគប្បី

www.budinst.gov.kh www.elibraryofcambodia.org

ដកនូវភូមិប្រទេសមិននៅប្រាសចាកត្រៃចីវរនោះ វាចានេះជាញត្តិគឺវាចាប្រកាសអោយសង្ឃជ្រាប ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភូមិប្រទេសឯណា ដែលសង្ឃសន្មតហើយ អោយជាដែនមិននៅប្រាសចាកត្រៃចីវរ « ឥឡូវ » សង្ឃដកនូវភូមិ ប្រទេសមិននៅប្រាសចាកត្រៃចីវរនោះ កិរិយាដកនូវភូមិប្រទេសមិននៅប្រាសចាក ត្រៃចីវរនោះ គួរដល់លោកដ៏មានអាយុអង្គណា លោកក៏មានអាយុអង្គនោះ ត្រូវឆ្លើយបកចុះ ។ ភូមិប្រទេសមិននៅប្រាសចាកត្រៃចីវរនោះដែលសង្ឃដករួចហើយគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្តីនេះ ដោយហេតុដែលសង្ឃស្ងៀមយ៉ាងនេះ ។

## បាលីសូធ្យ ដកសមានសំវាសសីមា

សុណាតុ មេ ភន្តេ សង្ឃោ , យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា . យទិ សង្ឃស្ស បត្តកល្លំ , សង្ឃោ តំ សីមំ សមូហនេយ្យ , ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ , យា សា សង្ឃេន សីមា

www.budinst.gov.kh www.elibraryofcambodia.org

**សម្មតា , សមានសំវាសា ឯកុបោសថា , សខេ្យា កំ សីមំ សម្ហានតិ យស្សាយស្មតោ ខមតិ , ឯតិស្សា សីមាយ សមានសំវាសាយ ឯកុបោសថាយ សមុគ្ឃាតោ សោ តុណ្ហស្ស , យស្ស នក្ខមតិ , សោ ភាសេយ្យ ។ សម្ហតា សា សីមា សខេ្យន សមានសំវាសា ឯកុបោសថា ខមតិ សខ្យស្ស , តស្មា តុណ្ហី , ឯវមេតំ ធារយាមិ ។**

« ពាក្យប្រែ » បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ សីមាឯណាដែលសង្ឃសន្មតហើយ អោយជាសីមាដ៏មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា បើសង្ឃកម្មនេះមានកាលដ៏សមគួរហើយ សង្ឃគប្បីដកនូវសីមានោះ វាចានេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ សីមាឯណាដែលសង្ឃសន្មតហើយ អោយជាសីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា « ឥឡូវ » សង្ឃដកនូវសីមានោះ កិរិយាដកនូវសីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវធ្លើយមកចុះ ។ សីមា មានសំវាសស្មើគ្នាមានឧបោសថជាមួយគ្នានោះ ដែល

www.budinst.gov.kh www.elibraryofcambodia.org

សង្ឃដកឬចហើយ គួរដល់សង្ឃព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្តីនេះ ដោយហេតុដែលសង្ឃស្ងៀមយ៉ាងនេះ ។

## បាលីសូត្រសន្មតសមានសំវាសសីមា

សុណាតុ មេ ភន្តេ សង្ឃោ , យាវតា សមន្តា និមិត្តា កិត្តិតា យទិ សង្ឃស្ស បត្តកល្លំ , សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នេយ្យ សមានសំវាសំ ឯកុបោសថំ , ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ , យាវតា សមន្តា និមិត្តា កិត្តិតា សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នតិ សមានសំវាសំ ឯកុបោសថំ , យស្សាយស្មតោ ខមតិ , ឯតេហិ និមិត្តេហិ សីមាយ សម្មតិ សមានសំវាសាយ ឯកុបោសថាយ , សោ តុណ្ហស្ស , យស្ស នក្ខមតិ , សោ ភាសេយ្យ ។ សម្មតា « សា » សីមា សង្ឃេន ឯតេហិ និមិត្តេហិ សមានសំវាសា ឯកុបោសថា , ខមតិ សង្ឃស្ស តស្មា , តុណ្ហី , ឯវមេតំ ធារយាមិ ។

www.budinst.gov.kh www.elibraryofcambodia.org

« ពាក្យប្រែ » បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ និមិត្តទាំងឡាយដែលគេកំណត់ទុកហើយ ដោយជុំវិញត្រឹមណា បើសង្ឃកម្មនេះមានកាលដ៏សមគួរហើយ សង្ឃគប្បីសន្មតសីមា អោយមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនោះ វាចានេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ និមិត្តទាំងឡាយដែលគេកំណត់ទុកហើយដោយជុំវិញត្រឹមណា « ឥឡូវ » សង្ឃសន្មតនូវសីមា អោយមានសំវាសស្មើគ្នា អោយមានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនោះ ។ កិរិយាសន្មតនូវសីមាអោយមានសំវាសស្មើគ្នា អោយមានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម « បើ » មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវឆ្លើយមកចុះ ។ សីមាដែលសង្ឃសន្មតហើយអោយមានសំវាសស្មើគ្នា អោយមានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមខ្ញុំចាំទុកនូវសេចក្តីនេះ ដោយហេតុដែលសង្ឃស្ងៀមយ៉ាងនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

## បាលីសូត្រសន្មតតិចីវរាវិប្បវាស

សុណាតុ មេ ភន្តេ សង្ឃោ, យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ សីមំ តិចីវរេន អវិប្បវាសំ សម្មន្នេយ្យ ឋបេត្វា គាមញ្ច គាមូបចារញ្ច, ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ, យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, សង្ឃោ តំ សីមំ តិចីវរេន អវិប្បវាសំ សម្មន្នតិ ឋបេត្វា គាមញ្ច គាមូបចារញ្ច ។ យស្សាយស្មតោ ខមតិ, ឯតិស្សា សីមាយ តិចីវរេន អវិប្បវាសាយ សម្មុតិ ឋបេត្វា គាមញ្ច គាមូបចារញ្ច សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតា សា សីមា សង្ឃេន តិចីវរេន អវិប្បវាសា ឋបេត្វា គាមញ្ច គាមូបចារញ្ច ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

www.budinst.gov.kh www.elibraryofcambodia.org

« ពាក្យប្រែ » បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំសីមាឯណាដែលសង្ឃសន្មតហើយ អោយមានសំវាសស្មើគ្នា អោយមានឧបោសថជាមួយគ្នា បើសង្ឃកម្មនេះ មានកាលដ៏សមគួរហើយ សង្ឃគប្បីសន្មតសីមានោះ អោយជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរលែងតែស្រុក និងឧបចារះនៃស្រុកចេញ វាចានេះជាញត្តិ គឺវាចាប្រកាសសង្ឃអោយជ្រាប ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំសីមាដែលសង្ឃសន្មតហើយ អោយមានសំវាសស្មើគ្នា អោយមានឧបោសថជាមួយគ្នា « ឥឡូវ » សង្ឃសន្មតនូវសីមានោះ អោយជាដែនមិននៅប្រាស ចាកត្រៃចីវរ វៀរលែងតែស្រុកនិងឧបចារះនៃស្រុកចេញ ។ កិរិយាសន្មតនូវ សីមានោះអោយជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរលែងតែស្រុកនិង ឧបចារះ នៃស្រុកចេញ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម ( ពើ ) មិនគួរដល់លោកដ៏មានអាយុអង្គនោះ ត្រូវឆ្លើយមកចុះ ។ សីមានោះដែលសង្ឃបានសន្មតហើយ អោយជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរលែងតែស្រុក និងឧបចារះនៃ

www.budinst.gov.kh www.elibraryofcambodia.org

ស្រុកចេញគួរដល់សង្ស័យព្រោះហេតុនោះ បានជាសង្ស័យស្ទើរ ខ្ញុំចាំទុកនូវសេចក្តីនេះ ដោយហេតុដែលសង្ស័យស្ទើរយ៉ាងនេះ ។

## ផ្លូវសុខ ៣ យ៉ាង

នាកាលថ្ងៃមួយ ព្រះពុទ្ធបរមគ្រូទ្រង់យាងទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីបានទតព្រះនេត្រទៅឃើញពួកក្មេងៗច្រើនគ្នាកំពុងតែចោមវាយពស់មួយ ទ្រង់ទតឃើញហើយត្រាស់សួរថា នែពួកក្មេងៗ ! នាំគ្នាធ្វើអ្វី ? ។ ពួកក្មេងៗទាំងនោះបានក្រាបទូលព្រះអង្គថា ពួកទូលព្រះបង្គំនាំគ្នាវាយពស់ ។ ព្រះអង្គត្រាស់សួរម្តងទៀតថា អ្នកឯងវាយវាព្រោះហេតុអ្វី ? ពួកក្មេងៗបានក្រាបទូលថាព្រោះខ្លាចវាខាំ ។ ព្រះអង្គត្រាស់ថា «មិនសមហេតុផលទេ» ។

**សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ**

**អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។**

**សុខកាមានិ ភូតានិ យោ ទណ្ឌេន ន វិហឹសតិ**

**អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខំ ។**

www.budinst.gov.kh www.elibraryofcambodia.org

សត្វទាំងឡាយណាដែលកើតមកហើយ សុទ្ធតែចង់បានសេចក្តីសុខ អ្នកណាស្វែងរកសេចក្តីសុខដើម្បីខ្លួនតែនៅប្រើហឹង្សាបៀតបៀនអ្នកដទៃដោយអាជ្ញាគឺដំបង ឬ ព្រនង់ អ្នកនោះគឺពិតជាមិនបានសេចក្តីសុខឡើយ ទោះជាបច្ចុប្បន្នក្តីទៅខាងមុខក្តី ។ លុះណាតែសត្វទាំងឡាយណាស្វែងរកសេចក្តីសុខដើម្បីខ្លួន តែមិនបៀតបៀនអ្នកដទៃដោយអាជ្ញាអ្នកនោះទើបបានសុខពិតប្រាកដទាំងបច្ចុប្បន្ននិងទៅខាងមុខ ។

**បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ**

**វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។**

បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួនដោយការធ្វើសេចក្តីទុក្ខដល់អ្នកដទៃ បុគ្គលនោះ រមែងច្រឡូកច្របល់ ដោយពៀរ គេចមិនផុតពីពៀរឡើយ ។

## ផ្លូវសុខមាន ៣ យ៉ាង

១_ **កាយិកសុខ** សេចក្តីសុខប្រព្រឹត្តទៅតាមផ្លូវកាយ គឺសំដៅយកការស្ថិតនៅត្រង់ជីវភាព រស់នៅស្រួល ត្រជាក់ត្រជុំរមនា មាន

www.budinst.gov.kh www.elibraryofcambodia.org

សុខុមាលភាព បរិបូណ៌ពុំសូវមានជំងឺតម្កាត់ រោគាព្យាធិបៀតបៀន ដោយចេះគោរពបានជាប់ជានិច្ចនូវពាក្យស្លោក ៣ យ៉ាងគឺ

១- រស់នៅស្អាត

២- ហូបស្អាត

៣- ផឹកស្អាត

២- **ចេតសិកសុខ** សេចក្ដីសុខប្រព្រឹត្តទៅតាមផ្លូវចិត្ត គឺម្នាក់ៗត្រូវតាំងចិត្ត រស់នៅក្នុងសុខសន្តិភាព នៅជិតគ្នាឬ ជាមួយគ្នា ត្រូវចេះប្រាស្រ័យ ទំនាក់ទំនងគ្នាល្អ ពេញចិត្តគ្នា មិនប្រកួតប្រកាន់គ្នា ចេះអត់ឱនគ្នា អធ្យាស្រ័យគ្នាទៅវិញទៅមក សាមគ្គីភាព មិត្តភាព ភាតរភាពល្អជាប់ជានិច្ច ឧស្សាហ៍ធ្វើបុណ្យបំពេញកុសល - ល - ដើម្បីកសាងចិត្តអោយស្អាតល្អរៀងខ្លួន ។

៣- **សម្ភារិកសុខ** សេចក្ដីសុខព្រោះមានសម្ភារៈសម្រាប់ប្រើប្រាស់ផ្គត់ផ្គង់ជីវភាព បរិបូណ៌ ។

www.budinst.gov.kh www.elibraryofcambodia.org

បើមានត្រឹមសេចក្ដីសុខតាមផ្លូវកាយ និងសេចក្ដីសុខតាមផ្លូវចិត្ត ប៉ុណ្ណោះមិនទាន់គ្រប់គ្រាន់ទេ ពិព្រោះមនុស្សកើតមកសុទ្ធតែចង់រស់ នៅដោយស្រួល ដែលចេះតែស្រួលទាំបាន លុះណាតែមានសម្ភារៈគ្រប់យ៉ាងសម្រាប់ប្រើប្រាស់ថែមទៀតទើបបាន ។ ដូច្នេះគេត្រូវតែខិតខំបង្កបង្កើនផលដំណាំកសិកម្មអោយបានច្រើន ផ្ដល់អោយរោងចក្រឧស្សាហកម្ម ផលិតចេញជាសម្ភារៈផ្សេងៗ សំប្ដូរហូបៀវសម្រាប់ប្រើប្រាស់តាមត្រូវការ ។

មានតែផ្លូវសុខ ៣ យ៉ាងនេះទេដែលយើងត្រូវជ្រើសរើសយកច្រកចេញ ដើរឆ្ពោះទៅដល់ទីដៅនៃគោលបំណងប្រាថ្នាបាន ។

*ដោយ សម្ដេចព្រះមង្គលទេពាចារ្យ* **អ៊ុំ ស៊ុំ**

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកផ្តួចផ្តើមកាន់ទិស

ក្នុងពិធីបុណ្យបញ្ចុះខ័ណ្ឌសីមាព្រះវិហារវត្ត គោករមិ្ពល

១. មជ្ឈិមេ (សីមាកន្ទុកិល)

- ឧបាសក ត្រឹយ៍ បេងហុង ឧបាសិកា ម៉ម ដួងសុជាតិ

ព្រមទាំងបុត្រធីតា

២. ទិសបូពិ

- មន្ត្រីរាជការ បុគ្គលិកនៃមន្ទីររៀបចំក្រុង និងសំណង់រាជធានីភ្នំពេញ
- មន្ត្រីរាជការ បុគ្គលិកនៃការិយាល័យសុរិយោដីរាជធានីភ្នំពេញ

៣. ទិសអគ្នេយ៍ ( វត្តព្រៃកសំរោង )

ប្រធានសង្ឃ យន់ ពុំ

លោកអាចារ្យ ចឹក ចក់

**គណៈកម្មការ :**

១. ស៊ូ សន

២. ជុំ កាន

៣. ឡាយ លី

ព្រមទាំងឧបាសក ឧបាសិកាចំណុះជើងវត្ត

www.budinst.gov.kh www.elibraryofcambodia.org

៤. ទិសឧត្តរ វត្តមហាឧត្តម៍ន

គណៈកម្មការអាចារវត្តព្រមទាំងពុទ្ធបរិស័ទចំណុះជើងវត្ត

៥. ទិសនិរតី វត្តឫស្សីសាញ់ វត្តព្រះធម្មក្រស័យ និងវត្តក្រពែង

អាចារ្យ យ៉ាង និងអាចារ្យ ឯម អាំ ព្រមទាំងពុទ្ធបរិស័ទចំណុះជើងវត្ត

- លោក ម៉ៃ សេង ( ចៅសង្កាត់ព្រៃ ស )
- លោក នៅ ចាន់ ( ចោមចៅ )

៦. ទិសបស្ចិម ភូមិជើងឯក

- លោកយាយ ណារី ព្រមទាំងពុទ្ធបរិស័ទក្នុងភូមិ

៧. ទិសពាយ័ព្យ វត្តព្រះពុទ្ធអរំណែក

គណៈកម្មការ ព្រមទាំងពុទ្ធបរិស័ទជើងវត្ត មាន :

១. សាន សេម
២. សាន រុំ
៣. យន សាន
៤. ខាន់ អុល
៥. ឯម យ៉េត
៦. ប៊ុត ខុំ
៧. ហាង ខុំ

៨. ទិសឧត្តរ-វត្តសំបូរមាស

www.budinst.gov.kh www.elibraryofcambodia.org

- លោកយាយសីល ១០ និងពុទ្ធបរិស័ទចំណុះជើងវត្ត

| | | | | | | | |
|---|---|---|---|---|---|---|---|
| - | លោក | គ្រុច | ផាន | | លោក | ស៊ឹម | គីន |
| - | លោក | ថោង | អេន | | - | ហាក់ | គួយ |
| - | - | ម៉ៃ | ម៉ុន | | - | ជាំ | វៀង |
| - | - | សុខ | ជា | | - | តូច | លន់ |
| - | - | អ៊ុក | សេងកន | | - | ឱ | សុខជា |
| - | - | យួន | សួផន | | - | អ៊ី | សុគង់ |
| - | - | ប៊ូ | សារ៉ន | | - | សិន | ស៊ិន |
| - | - | ប៊ុន | ច័ន្ទ | | - | វើក | សាមឿន |
| - | - | សាន | ស៊ុថាន់ | | - | វ៉ាត | ដុស |
| - | - | ហ៊ី | ឆាយ | | - | ទូច | តីន |
| - | - | ឱក | ផុន | | - | យិន | ប៉ស់ |
| - | - | ម៉ុល | យុន | | - | ស្រេក | រស |
| - | - | អោម | សំអាង | | | | |

## ៩. និសណ្ណសាន វត្តក្រពើហា និង វត្តព្រៃព្រាកបុស្សី

- ព្រះតេជគុណ វណ្ណា
- ព្រះតេជគុណ យឹម

ព្រមទាំងឧបាសក ឧបាសិកា ចំណុះជើងវត្តទាំងពីរ ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org